**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
~~~~~~~

**គាំងនាមប្រជារាស្ត្រខ្មែរ**

| | |
|---|---|
| តុលាការកំពូល<br>~~~~~<br>សភាព្រហ្មទណ្ឌ<br>សំណុំរឿងព្រហ្មទណ្ឌ<br>លេខ ២១៦<br>ចុះថ្ងៃទី០៥ខែតុលាឆ្នាំ២០២០<br>សាលដីកា<br>លេខ១៦០ "III"<br>ចុះថ្ងៃទី១១ខែមិថុនាឆ្នាំ២០២១ | |

**តុលាការកំពូល**

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ ដោយអង្គជំនុំជម្រះមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម ... ជាប្រធាន
២.ឯកឧត្តម ... ជាចៅក្រម
៣.ឯកឧត្តម ... ជាចៅក្រម
៤.ឯកឧត្តម ... ជាចៅក្រម
៥.ឯកឧត្តម ... ជាចៅក្រម

**ចៅក្រមរបាយការណ៍**

ឯកឧត្តម ... ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោកស្រី ...

**តំណាងមហាអយ្យការ**

ឯកឧត្តម ... ឋានៈជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលេខ១៩៥ ចុះថ្ងៃទី១៣ខែកក្កដាឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ **អបល** ដែលប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ៨០ ក្រIV "ណ" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

បុគ្គលប្តឹងសាទុក្ខ៖ ឈ្មោះ **អបល** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិម៉ុងបារាំង ឃុំរលាប្អៀរ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ទីលំនៅមុនពេលឃុំខ្លួនភូមិម៉ុងបារាំង សង្កាត់ឃុំរលាប្អៀរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មុខរបរលក់មីឆា ឪពុកឈ្មោះ ...(រ) ម្តាយឈ្មោះ ...(រ) ប្រពន្ធឈ្មោះ ... (រ) មានកូន០១នាក់ ទោសពីមុនគ្មាន ។ ឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ឆ្នាំង ។

-ដីកាបង្គាប់ខ្លួនបណ្តោះអាសន្នលេខ១០១៧/២០១៨ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨

**ជាប់ចោទពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ដល់ខែធ្នូ ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។
~~~~~~~

**អំពីអង្គហេតុ៖**

កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង១៤និង០០នាទី នៅចំណុចផ្លូវជាតិលេខ៥៣ ស្ថិតក្នុងភូមិស្រែតាដៃលិច ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំ កម្លាំងអធិការនគរបាលស្រុកទឹកផុស សហការជាមួយកម្លាំងជំនាញការិយាល័យប្រឆាំងគ្រឿងញៀន បានចុះបង្ក្រាបបទល្មើសជាក់ស្តែង០១ករណី គឺករណីជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបន្តចាប់ខ្លួនរហូតដល់ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ ជាលទ្ធផលឃាត់បានជនជាប់ចោទចំនួន០៥នាក់ គឺឈ្មោះ **បមករ**, ឈ្មោះ **លសខន**, ឈ្មោះ..., ឈ្មោះ **អបល** និងឈ្មោះ **វយស** និងដកហូតវត្ថុតាងមាន ម្សៅក្រាមពណ៌សថ្លា ជាសារធាតុញៀនមេតំហ្វេតាមីនសរុបសំនួន៩៦កញ្ចប់ សរុប(ទម្ងន់ ២៧០,១៦ក្រាម) ថ្នាំញៀនប្រភេទ WY ចំនួន១៨២គ្រាប់ ទម្ងន់(១៩,៦០ក្រាម) ទូរស័ព្ទចំនួន០៤គ្រឿង និងម៉ូតូចំនួន០២គ្រឿង ចំណែកឈ្មោះ **យសអ** បានគេចខ្លួនបាត់។

-បានឃើញសាលក្រមលេខ៦៣ "ឃ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ជនជាប់ចោទ៖

ក/.ឈ្មោះ **វយស** ភេទប្រុស អាយុ៣៣ឆ្នាំ មានពិរុទ្ធភាពពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ខែធ្នូ ឆ្នាំ២០១៨ ។

ខ/.ឈ្មោះ **អបល** ភេទប្រុស អាយុ២៣ឆ្នាំ

គ/.ឈ្មោះ **បមករ** ភេទប្រុស អាយុ២៨ឆ្នាំ

ឃ/.ឈ្មោះ **លសខន** ភេទប្រុស អាយុ២៣ឆ្នាំ

ង/.ឈ្មោះ **យសអ** ភេទប្រុស អាយុ៣៧ឆ្នាំ

មានពិរុទ្ធភាពពីបទបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ខែធ្នូ ឆ្នាំ២០១៨។

២.ផ្តន្ទាទោសជនជាប់ចោទ៖

ក/.ឈ្មោះ **វយស** ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិវៀតណាម ដាក់ពន្ធនាគារកំណត់១៥(ដប់ប្រាំ)ឆ្នាំពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ខែធ្នូ ឆ្នាំ២០១៨ ។

ខ/.ឈ្មោះ **អបល** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៤(បួន)ឆ្នាំ។

គ/.ឈ្មោះ **បមករ** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០២(ពីរ)ឆ្នាំ និង ០៦ (ប្រាំមួយ)ខែ។

ឃ/.ឈ្មោះ **លសខន** ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០២(ពីរ)ឆ្នាំ និង ០៦ (ប្រាំមួយ)ខែ។

ង/.ឈ្មោះ **យសរអ** ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣(បី)ឆ្នាំ។

**ពីបទ *រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន*** តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ០៤-០៥-០៦ ខែធ្នូ ឆ្នាំ២០១៨។

៣.បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ **យសរអ** ដែលមានសាវតារជាតិខាងលើ។

៤.រឹបអូសវត្ថុតាងមានក្នុងសាលដីកាបង្គាប់ឲ្យតម្កល់វត្ថុតាងលេខ២៤៨៣ អ.យ/២០១៨ តាមបញ្ញត្តិមាត្រា៩៣ និងមាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ ***វយស***, ឈ្មោះ **អបល**, ឈ្មោះ **បមករ** និងឈ្មោះ **លសខន** ។ កំបាំងមុខជនជាប់ចោទ ឈ្មោះ **យសរអ** និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ទុកសិទ្ធិឲ្យប្តឹងទាស់និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញណ្តឹងឧទ្ធរណ៍លេខ ៤៩ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ ***វយស*** ក្នុងការប្តឹងឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៦៣ "ឃ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញបណ្តឹងឧទ្ធរណ៍០៨ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ **អបល** ក្នុងការប្តឹងឧទ្ធរណ៍មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៦៣ "ឃ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៥០ក្រIV "ណ" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.បដិសេធពាក្យបណ្តឹងឧទ្ធរណ៍លេខ៤៩ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ ***វយស*** និងពាក្យបណ្តឹងឧទ្ធរណ៍០៨ ចុះថ្ងៃទី០៤ ខែកុម្ភៈឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ **អបល** ចោលជាអសារបង់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៣ "ឃ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ឆ្នាំងទុកជាបានការ។

-បានឃើញបណ្តឹងសាទុក្ខលេខ១៩៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ **អបល** ក្នុងការប្តឹងសាទុក្ខ មិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៥០ ក្រIV "ណ" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញត្រង់ចំណុចសេចក្តីសម្រេចទាំងមូលនៃសាលដីកា។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍ឡើងរាយការណ៍

-តំណាងអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋាននិងប្តឹងសុំថា ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ដែលតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល គឺមានសំអាងហេតុនិងភស្តុតាងត្រឹមត្រូវតាមច្បាប់ ព្រោះថា អំពើប្រព្រឹត្តបទល្មើសជាអំពើជាក់ស្តែង ហើយពេលចុះបង្ក្រាបបទល្មើសសមត្ថកិច្ចចាប់យកបានជាវត្ថុតាងរួមមាន៖ ម្សៅក្រាមពណ៌ស ជាសារធាតុមេតំហ្វេតាមីនចំនួន៩៦កញ្ចប់ទម្ងន់ ២៧០,១២ ក្រាម, ញៀនប្រភេទ WY ចំនួន១៨២គ្រាប់ ទម្ងន់១៩,៦០ក្រាម។ បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ **វយស** សុំបន្ថយទោសត្រឹម៧ឆ្នាំ៦ខែ ហើយជនជាប់ចោទឈ្មោះ **អបល** សុំបន្ថយទោសត្រឹម២ឆ្នាំ។ ម៉្យាងទៀតថ្នាំញៀនដែលដកហូតបានពីជនជាប់ចោទឈ្មោះ **វយស** មានកម្រិតសារធាតុសុទ្ធចំនួន២០៤,១០៧ ក្រាម និងថ្នាំញៀនដែលដកហូតបានពីជនជាប់ចោទឈ្មោះ **អបល** មានកម្រិតសារធាតុសុទ្ធចំនួន១៤,១០៦ក្រាម ដូចមាននៅក្នុងសំអាងហេតុចំណុចទី២ និងទី៣ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់។ ចំពោះបណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ **អបល** ពុំបានដាក់សារណាការពារជូនតុលាការតាមច្បាប់ទេ។ តំណាងមហាអយ្យការស្នើសុំតុលាការកំពូលសម្រេចតម្កល់សាលដីកាលេខ៥០ ក្រIV "ណ" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ទុកជាបានការដដែល ។

-ជនជាប់ចោទឈ្មោះ **អបល** បានឆ្លើយមូលហេតុដែលខ្លួនប្តឹងសាទុក្ខមកតុលាការកំពូល ពីព្រោះសាលាដំបូងខេត្តកំពង់ឆ្នាំងបានផ្តន្ទាទោសខ្លួនចំនួន៤(បួន)ឆ្នាំ។

សំណូមពរ សូមឲ្យតុលាការកំពូលជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

## តុលាការកំពូល

១.យល់ឃើញថាបណ្តឹងសាទុក្ខលេខ១៩៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ **អបល** ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គតុលាការ និងមាត្រា៤២០ នៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌ។

២.យល់ឃើញថា ចម្លើយរបស់ជនជាប់ចោទនាពេលសវនាការថា មូលហេតុដែលខ្លួនប្តឹងសាទុក្ខនេះ គឺខ្លួនសុំបន្ធូរបន្ថយទោសមកនៅត្រឹម២ឆ្នាំវិញ ដោយខ្លួនមិនមានមូលដ្ឋានខាងផ្លូវច្បាប់មកគាំទ្រការសុំរបស់ខ្លួននោះទេ។ ដូច្នេះ តុលាការកំពូលមិនមានគតិយុត្តដូចមានក្នុងមាត្រា៤៣៦ នៃក្រមនីតិវិធីដែលបញ្ញត្តិអំពីសេចក្តីសម្រេចលើបញ្ហាគតិយុត្តថា "តុលាការត្រូវសម្រេចលើបញ្ហាផ្លូវច្បាប់ដែលលើកឡើងដោយអ្នកប្តឹងសាទុក្ខនិងមានរៀបរាប់ក្នុងសារណា" ក្នុងរឿងនេះជនជាប់ចោទមិនបានដាក់សារណាបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ខ្លួនមកតុលាការកំពូលតាមដីកាបង្គាប់ឲ្យដាក់សារណាបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខនោះឡើយ ។ ម្យ៉ាងទៀតបណ្តឹងសាទុក្ខដោយលើកមកមូលហេតុសុំបន្ធូរបន្ថយទោសនោះ មិនមានបញ្ញត្តិក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ហើយវាខុសសមត្ថកិច្ចទៀតផង ពីព្រោះការពិនិត្យ និងផ្តល់ការបន្ធូរបន្ថយទោសត្រូវធ្វើឡើង នៅក្រោយសាលក្រមសាលដីកាចូលជាស្ថាពរ និងនៅដំណាក់កាលអនុវត្តសាលក្រមសាលដីកាតាមច្បាប់ស្តីពីពន្ធនាគារ និងបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធ។

៣.យល់ឃើញថា នាពេលសវនាការនៅចំពោះមុខតុលាការកំពូលលោក **មបរ** ជាមេធាវីការពារឲ្យជនជាប់ចោទបានអវត្តមាន តែបានដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដោយបានលើកពីអង្គហេតុ និងភស្តុតាងថា "ជនជាប់ចោទឈ្មោះ **អបល** បានសារភាពថា គាត់ពិតជាបានធ្វើសកម្មភាព តែគាត់មិនបានសារភាពថា គាត់បានបំពានមាត្រា៤០ទេ។ គាត់បានទៅយកថ្នាំញៀនដែលគេប្លុងចោលទៅឲ្យអ្នកទិញ ក្រោយពីឈ្មោះ **យសអ** បានប្រាប់ឲ្យគាត់ទៅយក" ក្នុងអង្គហេតុនេះទោះបីវាអាចពាក់ព័ន្ធនឹងការរក្សាទុក ឬការដឹកជញ្ជូនក៏មិនត្រូវដែរ ពីព្រោះគាត់មិនបានរក្សាទុក គឺគ្រាន់តែទៅយករួចដឹកឲ្យគេ។ ទោះបីជាគាត់ប្រព្រឹត្តជាការដឹកជញ្ជូនមែន តែក៏មិនមែនជួញដូរដែរ ពីព្រោះគាត់បានផលពីអំពើនោះគឺបានជក់ តែមិនមែនដើម្បីចំណេញប្រាក់ក្នុងខ្លឹមសារជួញដូរទេ ដូច្នេះលោក **អបល** មិនបានប្រព្រឹត្តផ្ទុយនឹងមាត្រា៤០ទេ នោះតុលាការកំពូលពិចារណាឃើញថា សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទធ្វើឡើងមានភាពច្របូកច្របល់ ទទួលស្គាល់អង្គហេតុចោទប្រកាន់ផង បដិសេធផង ។

៤.យល់ឃើញថា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់មេធាវីការពារជនជាប់ចោទបានលើកឡើងអះអាងថា បទចោទប្រកាន់នេះគួរធ្វើសម្រាប់តែឈ្មោះ **យសអ** ដោយមិនត្រូវចោទប្រកាន់ជារួម ដោយមិនពិចារណាលើអង្គហេតុរបស់ជនជាប់ចោទនីមួយៗទេ។ ការធ្វើបែបនេះវាផ្ទុយទៅនឹងគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវ។ ការធ្វើបែបនេះ អាចផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្តីសម្រេចដោយយោងតាមបទបញ្ញត្តិមាត្រា៣៥៧នៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌនោះ តុលាការកំពូលយល់ឃើញថាគឺជាអំណះអំណាងមិនមានមូលដ្ឋានសំអាងនោះទេ ដោយហេតុថានៅក្នុងនីតិវិធីក្រមព្រហ្មទណ្ឌ ក៏ដូចជាក្រមព្រហ្មទណ្ឌដែល មិនមានបទបញ្ញត្តិអំពីគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវនោះទេ មានតែបញ្ញត្តិអំពីគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវក្នុងមាត្រា៩៦នៃក្រមព្រហ្មទណ្ឌ ។ ម្យ៉ាងទៀត សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទមិនបានចង្អុលបង្ហាញឲ្យតុលាការកំពូលឃើញថា តើផ្នែកសំអាងហេតុត្រង់ចំណុចណានៃសាលក្រមរបស់

សាលាដំបូង ឬសាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ **អបល** មានភាពផ្ទុយគ្នាទៅនឹងផ្នែកសេចក្តីសម្រេចពាក់ព័ន្ធនឹងជនជាប់ចោទរូបនេះឡើយ ។

៥.យល់ឃើញថា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់មេធាវីការពារជនជាប់ចោទបានលើកឡើងអះអាងថា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍ហាក់ផ្តោតចម្បងទៅលើបរិមាណគ្រឿងញៀនសម្រាប់ដាក់ទោស។ ប៉ុន្តែចំនួនគ្រឿងញៀនមានភាពមិនច្បាស់លាស់ទេនោះ តុលាការកំពូលពិចារណាឃើញថា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍ពុំមែនជាកម្មវត្ថុឬជាមូលហេតុនៃបណ្តឹងសាទុក្ខទេ។ ចំណែកបរិមាណសុទ្ធនៃសារធាតុញៀនពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ **អបល** មានទម្ងន់១៤,១០៦ក្រាម មានឯកសារភស្តុតាងលើកបង្ហាញបញ្ជាក់យ៉ាងត្រឹមត្រូវក្នុងសំអាងហេតុ ត្រង់ចំណុចទី៧ ផ្នែកពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ **អបល** នៃសាលក្រមព្រហ្មទណ្ឌលេខ៦៣"យ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ បានសម្រេចតម្កល់ទុកជាបានការតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ៥០ ក្រIV "ណ" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលទទួលការប្តឹងសាទុក្ខប្រឆាំងនេះ ដូច្នេះឃើញថាសេចក្តីសន្និដ្ឋានរបស់មេធាវីត្រង់ចំណុចនេះទំនងជាមិនបានអានសាលក្រម និងសាលដីកាដែលទទួលរងការប្តឹងសាទុក្ខ ។

៦.យល់ឃើញថា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់មេធាវីការពារជនជាប់ចោទបានលើកឡើងអះអាងថា ប្រសិនបើមិនមានបទល្មើសកើតមានទេ តុលាការកំពូលតាមអំណាននៃមាត្រា៤៤០ សូមសម្រេចដោយមិនចាបាច់បង្វិលទៅសាលាឧទ្ធរណ៍វិញ ដើម្បីកាត់បន្ថយការចំណាយពេលនៃការប្តឹងជាថ្មី ឬពន្យាពេលជាបន្ត ដែលលោក **អបល** បានជាប់ចោទជាងពីរឆ្នាំ ហើយនេះជាសមាមាត្រនិងទង្វើនៃការចូលរួមក្នុងល្បែងអបាយមុខក្នុងសង្គម និងសំណូមពរសុំឲ្យតុលាការកំពូលសម្រេចដោយសម្រេចឲ្យឈ្មោះ **អបល** រួចខ្លួននោះ តុលាការកំពូលពិចារណាឃើញថា ជាសេចក្តីសន្និដ្ឋានមិនមានភាពច្បាស់លាស់ ច្របូកច្របល់ និងផ្ទុយគ្នាដោយហេតុគាត់បានប្រើប្រយោគថា "ប្រសិនបើមិនមានបទល្មើសកើតមានទេ" និង "ជាសមាមាត្រនិងទង្វើនៃការចូលរួមក្នុងល្បែងអបាយមុខក្នុងសង្គម" ។

៧.យល់ឃើញថាបណ្តឹងសាទុក្ខលេខ ១៩៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ **អបល** ធ្វើឡើងពុំមានមូលហេតុបណ្តឹងសាទុក្ខដូចមានបញ្ញត្តិក្នុងមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ដែលជាហេតុតុលាការកំពូលសម្រេចបដិសេធបណ្តឹងសាទុក្ខនេះ យោងតាមបញ្ញត្តិមាត្រា៤៣៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនិតិវិធីព្រហ្មទណ្ឌ។

៨.យល់ឃើញថា សេចក្តីសន្និដ្ឋានផ្ទាល់មាត់នាពេលសវនាការរបស់តំណាងមហាអយ្យការអមតុលាការកំពូល មានខ្លឹមសារប្រហាក់ប្រហែលគ្នានឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលបានលើកឡើងថា បណ្តឹងសាទុក្ខលេខ១៩៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ **អបល** ធ្វើឡើងក្នុងកំណត់ច្បាប់។ ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ដែលបានតម្កល់សាលក្រមសាលាដំបូងទុកជាបានការ

ដែលសាលក្រមរបស់សាលាដំបូងមានសំអាងហេតុ និងភស្តុតាត្រឹមត្រូវតាមច្បាប់។ ថ្នាំញៀនដែលដកហូតបាន ពីជនជាប់ចោទឈ្មោះ **អបល** មានកម្រិតសារធាតុសុទ្ធ១៤,១០៦ក្រាម ដូចមានលើកបង្ហាញក្នុងសំអាងហេតុ ត្រង់ចំណុចទី២ និងទី៣ នៃសាលដីការរបស់សាលាឧទ្ធរណ៍ និងប្តឹងសុំតុលាការកំពូលសម្រេចតម្កល់ សាលដីកាព្រហ្មទណ្ឌលេខ៥០ ក្រIV "ណ" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ទុកជាបានការនោះ គឺជាសេចក្តីសន្និដ្ឋាន មានមូលដ្ឋានសំអាងលើអង្គហេតុ ភស្តុតាងនិងអង្គច្បាប់ត្រឹមត្រូវ សមស្របហើយ ហើយក៏ស្របទៅនឹងផ្នែក សំអាងហេតុត្រង់ចំណុចផ្សេងទៀតរបស់តុលាការកំពូលដែរ ។

៩.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៥០ ក្រIV "ណ" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវនឹងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១.បដិសេធទាំងស្រុងនូវបណ្តឹងសាទុក្ខលេខ១៩៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ របស់ជន ជាប់ចោទឈ្មោះ **អបល** ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៥០ក្រIV "ណ" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់សភា ព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ នូវផ្នែកដែលពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ **អបល** ទុកជាបានការ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ និងប្រកាសសវនាការជា សាធារណៈនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ។

| | | |
|---|---|---|
| ឯកឧត្តម | ... | ជាប្រធាន |
| ឯកឧត្តម | ... | ជាចៅក្រម |
| ឯកឧត្តម | ... | ជាចៅក្រម |
| ឯកឧត្តម | ... | ជាចៅក្រម |
| ឯកឧត្តម | ... | ជាចៅក្រម |
| លោកស្រី | ... | ជាក្រឡាបញ្ជី |

**ប្រធានអង្គជំនុំជម្រះ** **ក្រឡាបញ្ជី**

.. ..